សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០២ លេខ ២៤៥ ចេញផ្សាយថ្ងៃ ពុធ ទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨

## ស្លាព្រះហស្តសម្តេចឪទទួលរងនូវការបំផ្លាញឱ្យរលាយជាស្ថាពរដោយស្លាដៃបុរសខ្លាំងនៃកម្ពុជាហើយ


សម្តេចព្រះ នរោត្តម សីហនុ


សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ


លោក ញឹក ប៊ុនឆៃ

ដោយ : សច្ចៈ

គណបក្សហ៊្វុនស៊ិនប៉ិច គឺជាគណបក្ស ដែលបង្កើតឡើង ដោយសម្តេចឪ ព្រះ*នរោត្តម សីហនុ* កាលពីដើមទសវត្សរ៍ឆ្នាំ១៩៨០ ប្រឆាំងនឹងពួកចោរយួនឈ្លានពានលើទឹកដីខ្មែរ ។ ហ៊្វុនស៊ិនប៉ិច ដែលធ្លាប់ឈ្នះ

**តទៅទំព័រ២ ស**

## ហ៊ុន សែន បញ្ជាចំអកឱ្យអនុប្រធាន ង-៧០ ជាង២០នាក់រៀនក្បួនទ័ពដើម្បីទៅសមរភូមិ


នាយករដ្ឋមន្ត្រី ហ៊ុន សែន


កងទាហាន ង-៧០ កំពុងតម្រង់ជួរអង់ចាំបញ្ជា

ដោយ : សុរ្យាវីរិយ៍

នាយករដ្ឋមន្ត្រីដ៏កំសាក នៃប្រទេសខ្មែរ លោក*ហ៊ុន សែន* បានបញ្ជាបែបចំអក ឱ្យអនុប្រធានកងអង្គរក្សនៃកងពលតូច ង-៧០ ប្រមាណ២០នាក់ចូលសាលាហ៊្វឹកហ្វឺន ដើម្បីត្រៀមខ្លួន ទៅតំបន់ចោរសៀមឈ្លាន

**តទៅទំព័រ២ ខ**

## ក្រសួងព័ត៌មានខ្មែរឆ្លើយតបនឹងការចុះផ្សាយ របស់ កាសែតបាងកកប៉ុស្តិ៍


លោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាល ហ៊ុន សែន

ដោយ : រតនៈ

ក្រសួងព័តិមាន នៃប្រទេសកម្ពុជាបានឆ្លើយតបភ្លាមៗទៅនឹងកាសែតបាងកកប៉ុស្តិ៍ របស់សៀម ដែលបានដកស្រង់សម្តីលោកនាយករដ្ឋមន្ត្រី ដ៏កំសាក *ហ៊ុន សែន* ដែលបាននិយាយកាលពីថ្ងៃច័ន្ទ នៅទីស្តីការក្រសួងការបរទេស ពាក់ព័ន្ធទៅ

**តទៅទំព័រ៣ គ**

## គណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សទាមទារឱ្យមានកំណែទម្រង់ច្បាប់បោះឆ្នោតនិងធ្វើយ៉ាងណាឱ្យមានលក្ខន្តិកៈតួនាទីស្របច្បាប់ដល់បក្សប្រឆាំង


លោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី


លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស


លោក សុន ឆ័យ អ្នកនាំពាក្យគណបក្សសមរង្ស៊ី


ទិដ្ឋភាពនៃកិច្ចប្រជុំសភាកាលពីអាណត្តិទី៣កន្លងមក

ដោយ : វិសាល

គណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សបានធ្វើការទាមទាររួមគ្នាឱ្យមានការកែទម្រង់ច្បាប់បោះឆ្នោត និងទាមទារឱ្យមានលក្ខន្តិកៈ និងតួនាទីស្របច្បាប់ដល់គណបក្សប្រឆាំង។

ការទាមទារបែបនេះត្រូវបានធ្វើឡើងនៅក្នុងជំនួបពិសេសមួយកាលពីរសៀលថ្ងៃច័ន្ទកន្លងទៅរវាងលោក *John Negro-*

**តទៅទំព័រ៤ ម**

## ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកថានឹងផ្តល់ថវិកាជាលើកដំបូងដល់សាលាក្តីខ្មែរក្រហម



លោក John Negroponte ឧបការី រដ្ឋមន្ត្រីការបរទេសអាមេរិក


អតីតសមមិត្ត ខៀវ សំផន


អតីតសមមិត្ត នួន ជា

ដោយ : ជ.ឧត្តម

មុនពេលចាកចេញពីប្រទេសកម្ពុជាក្រោយបញ្ចប់ទស្សនកិច្ចជាផ្លូវការរួចមកឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកលោក John Negroponte បានធ្វើសន្និសីទកាសែតមួយកាលពីព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ នៅក្នុងស្ថានទូតអាមេរិកដោយលោកបានលើកឡើងនូវសេចក្តីរាយការណ៍មួយចំនួនដែលជា

**តទៅទំព័រ៤ ន**

## រដ្ឋាភិបាល ហ៊ុន សែន ចាញ់បោកសៀមហើយ ចាញ់បោកខ្លួនឯងទៀតក្នុងរឿងសៀមឈ្លានពានកម្ពុជា


ទាហានឈុតខ្មៅសៀមនៅតែបន្តឈ្លានពានទឹកដីប្រទេសកម្ពុជា


ទាហានឈុតខ្មៅសៀមធ្វើរបងនៅប្រាសាទតាមាន់ធំ

ដោយ : គ.អរពិន្ទ

នរណាៗក៏គេដឹងដែរថាការដែលទាហានសៀមហ៊ានបំពានយ៉ាងគឃ្លើនលើកគ្នាឈ្លានពានចូលកាន់កាប់ដីខ្មែរដំបូងឡើយនៅវត្តកែវសិក្ខាគិរីស្វារៈក្នុងតំបន់ប្រាសាទព្រះវិហារកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ ហើយបន្តរាលដាលទៅតំបន់ផ្សេងៗទៀតដូចជាប្រាសាទតាមាន់ធំ រួចមកប្រាសាទតាក្របី

**តទៅទំព័រ៣ ខ**

## ការបោះឆ្នោតកញ្ចប់ជាសញ្ញាថា គណបក្សប្រជាជនកំពុងតែមានបញ្ហាផ្ទៃក្នុង

ដោយ : គ.រដ្ឋា

ទន្ទឹមពេលដែលគណបក្សប្រជាជន នៃលោក *ហ៊ុន សែន* មានផែនការដាក់ឱ្យមានការបោះឆ្នោតកញ្ចប់ជ្រើសតាំងប្រធានម្នាក់ និងអនុប្រធាន២នាក់នៃសភាជាតិជាមួយគ្នានឹងការបោះឆ្នោតជ្រើសតាំងនាយករដ្ឋមន្ត្រីពីគណបក្សនេះតំណាលគ្នា លើបញ្ជីរួម ទាំងពេលដែលគណបក្សនេះត្រូវគេប្រកាសថាឈ្នះបានអាសនៈសភាដល់ទៅ៩០ ហើយមិនមានអ្វីគួរឱ្យព្រួយនោះ របៀបធ្វើការនេះនាំឱ្យមានការកាត់យល់ថាគណបក្សនេះមានបញ្ហាផ្ទៃក្នុង។

បណ្ឌិត *ឡៅ ម៉ុងហៃ* អ្នក

**តទៅទំព័រ២ ម**

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្អំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់អ្ពល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បែត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្អាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : **012 363 331, 016 719 616,**

*បរិយាយថ្ងៃនេះ*

## អឺរ៉ុប អាមេរិកក៏មានកង្វល់ដែរ ក្រែងកម្ពុជាក្រោមអំណាច ហ៊ុន សែន ដើរតាមផ្លូវភូមាផ្តាច់ការ

ដោយ : ហង្ស ច្រាផ្លា

ការចូលមកកម្ពុជាក្នុងទស្សនកិច្ច៣ថ្ងៃ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក John Negroponte ទាំងបានជួបជាមួយមេដឹកនាំនៃគណបក្សប្រឆាំង និយាយអំពីរឿងវាសនាប្រជាធិបតេយ្យនៅកម្ពុជានោះ ក៏ធ្វើឱ្យមានការចាប់អារម្មណ៍ជាពិសេសដំណើរការប្រជាធិបតេយ្យនៅ

**តទៅទំព័រ៤ ក**

**តមកពីទំព័រ១ ស**

ឆ្នោតភ្លូកទឹកភ្លូកដី កាលពីឆ្នាំ១៩៩៣នោះ បានក្លាយជាគណបក្សដ៏តូចជាងគេ និងស្ទើរតែរលាយហិនហោចជាស្ថាពរនៅក្នុងការបោះឆ្នោត អាណត្តិទី៤ ដោយសារតែភាពកំសោយ នៃសម្តេចក្រុមព្រះ មុនថ្ងៃទី១៨ តុលា ២០០៦ ។

ការចុះខ្សោយ ពីការបោះឆ្នោតមួយ ទៅការបោះឆ្នោតមួយរបស់ហ៊្វុនស៊ិនប៊ិចគឺដោយសារសម្តេចក្រុមព្រះ យកឆន្ទៈរាស្ត្រខ្មែរ ទៅលក់ឱ្យលោក *ហ៊ុន សែន* ជាថ្នូរនឹងអំណាច, លាភសក្ការៈ ដូចជាស្រី ស្រា និងដុល្លារជាដើម។ ជាមួយគ្នានោះ,ហ៊្វុនស៊ិនប៊ិចទទួលរងការបំផ្លាញយ៉ាងដំណំ ពីលោក*ហ៊ុន សែន* គឺតាំងពីឆ្នាំ១៩៩៧ដែលលោក*ហ៊ុន សែន* ទិញមេទ័ពសំខាន់ៗមួយចំនួន ដែលមិនសប្បាយចិត្តជាមួយនឹងសម្តេចក្រុមព្រះ រហូតធ្វើឱ្យគណបក្សនេះ បែកបាក់ជាកង់ៗនៅមុនការបោះឆ្នោតឆ្នាំ១៩៩៨ ជាពិសេស ក្រោយពីរដ្ឋប្រហារដ៏បង្ហូរឈាមមួយ កាលពីថ្ងៃទី៥-៦ កក្កដា ១៩៩៧ ។

ទោះបីជាហ៊្វុនស៊ិនប៊ិច ធ្លាក់ចុះពីការបោះឆ្នោតមួយ ទៅការបោះឆ្នោតមួយទៀត យ៉ាងណាក៏ដោយ ក៏សម្តេចក្រុមព្រះ ដែលតាំងខ្លួនឯង ជាប្រធានមួយជីវិតនៃគណបក្សនេះ មិនកែខ្លួនដែរ,ហើយបន្តភ្លើតភ្លើនជាមួយស្រី ស្រា ដុល្លារ មិនស្កប់ស្កល់ឡើយ ដោយសារតែភាពលោភលន់ ភ្លេចប្រពន្ធនិងកូននេះគឺដើម្បីកើបដុល្លារយកទៅបំប៉នស្រីក្មេង ដូចជាអ្នកម្នាង*អ៊ុក ផល្លា* និងបរិវារកញ្ញាមួយចំនួនទៀត ដែលជាស្រីកំណាន់ចិត្តរបស់ព្រះអង្គ ។

ភាពភ្លើតភ្លើន ដែលធ្វើឱ្យអតីតអ្នកតស៊ូ ព្រួយបារម្ភអំពីការរលាយ ស្នាព្រះហស្ថរបស់សម្តេចឪព្រះ*នរោត្តម សីហនុ* នេះហើយ បានជាមានចលនាមួយ នៅថ្ងៃទី១៨ តុលា ឆ្នាំ២០០៦ ដែលក្រុមប្រឹក្សាជាតិនៃហ៊្វុនស៊ិនប៊ិច ប្រមាណ៦០០នាក់ ធ្វើកំណែទំរង់ស៊ីជំរៅ គឺហាម មិនឱ្យសម្តេចក្រុមព្រះសំរេចការងារធំៗ របស់គណបក្សដោយអត្តនោម័ត ដូចជាពេលមុនទៀត ។ កំណែទំរង់នេះ បានធ្វើឱ្យសម្តេចក្រុមព្រះខឹង ហើយបបួលមន្ត្រីឡេមឡឺមប៉ុន្មាននាក់ទៅបង្កើតគណបក្សថ្មីពីហ៊្វុនស៊ិនប៊ិច ។

ក្រោយព្រឹត្តិការណ៍ ថ្ងៃទី១៨ តុលា ២០០៦, ហ៊្វុនស៊ិនប៊ិច ទទួលរងការវាយប្រហារពីសម្តេចក្រុមព្រះ យ៉ាងចាស់ដៃ ។ ប៉ុន្តែហ៊្វុនស៊ិនប៊ិច ដែលនៅសល់មេទ័ពសំខាន់ៗ ដូចឧត្តមសេនីយ៍*ញឹក ប៊ុនឆៃ,ខាន់ សាវឿន, ហ៊ុន ភឿង* ជាដើម នោះខំប្រឹងប្រែង ដណ្តើមបានអាសនៈចំនួន២ នៅក្នុងការបោះឆ្នោតជាតិអាណត្តិទី៤ ស្មើនឹងគណបក្សនរោត្តម រណឫទ្ធិ របស់សម្តេចក្រុមព្រះដែរ ។

ទោះបីជា ហ៊្វុនស៊ិនប៊ិចបែកបាក់ស្ទើរតែរលាយយ៉ាងណាក៏ដោយ ក៏ហ៊្វុនស៊ិនប៊ិចគេចមិនផុត អំពីការទទួលរងការព្យាយាមបំផ្លាញ ពីលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដែរ គឺតាមរយៈ ជ្រើសរើសយកហ៊្វុនស៊ិនប៊ិច ជាដៃគូចម្រុះនៅក្នុងរដ្ឋាភិបាល ។

អ្នកវិភាគនិយាយថា លោក*ហ៊ុន សែន* ព្យាយាមបំផ្លាញហ៊្វុនស៊ិនប៊ិចនេះ គឺដោយសារតែគាត់ដឹងថា ហ៊្វុនស៊ិនប៊ិចជាស្នាព្រះហស្ថ របស់សម្តេចឪ ពីព្រោះស្នាព្រះហស្ថសម្តេចឪជាច្រើនទៀត ក៏ត្រូវលោក*ហ៊ុន សែន*បំផ្លាញដែរ ពិសេសស្ពានអូឡាំពិកជាដើម គឺត្រូវលោក*ហ៊ុន សែន* លក់ឱ្យក្រុមហ៊ុនចិនតៃវ៉ាន់ ធ្វើសំណង់ផ្ទះល្វែង និងអគារពាណិជ្ជកម្ម នៅកាច់ជ្រុងខាងលិច ឆៀងខាងជើងទៀតផង ។

លោក*ហ៊ុន សែន* បានថ្លែងជាចំហហើយថា លោកនឹងធ្វើរដ្ឋាភិបាលចម្រុះ ជាមួយគណបក្សហ៊្វុនស៊ិនប៊ិច *ញឹក ប៊ុនឆៃ* ដែលការអះអាងនេះ, លោក*ហ៊ុន សែន* ចង់បំបែកហ៊្វុនស៊ិនប៊ិច ដែលកាន់តែខ្សោយហើយនោះជាពីរក្រុមទៀត ។ សម្តីលោក*ហ៊ុន សែន* នេះ ត្រូវបានគេមើលឃើញថា ជាចេតនាយ៉ាងច្បាស់ក្នុងការបំផ្លាញហ៊្វុនស៊ិនប៊ិច ដោយមិនលាក់លៀម និងលោក*ហ៊ុន សែន*ចង់អោយមន្ត្រីហ៊្វុនស៊ិនប៊ិច គាំទ្រលោក*កែវ ពុទ្ធរស្មី* ប្រធានគណបក្សនេះខឹង ហើយហែកហ៊្វុនស៊ិនប៊ិចចែកគ្នា ជាមួយលោក*ញឹក ប៊ុនឆៃ* តាំងពីពេលនេះទៅ ។

អ្នកចាស់ទុំហ៊្វុនស៊ិនប៊ិច បាននិយាយថា សម្តីលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដែលថា ធ្វើរដ្ឋាភិបាលចម្រុះ ជាមួយហ៊្វុនស៊ិនប៊ិចលោក*ញឹក ប៊ុនឆៃ* នេះ វាដូចជាគាត់ សំពងអ្នកគាំទ្រព្រះរាជបល្ល័ង្ក ខ្សែលោក*កែវ ពុទ្ធរស្មី* យ៉ាងច្បាស់ក្រឡែត, ហើយអាក្រក់ ជាងនេះទៀតនោះ គឺលោក*ហ៊ុន សែន* ហែកមន្ត្រីហ៊្វុនស៊ិនប៊ិច ក្រុមលោក*ញឹក ប៊ុនឆៃ* ទៀត ដែលជាក្រុមមួយចំហៀង ពីលោក*កែវ ពុទ្ធរស្មី* នោះ ។ ការហែកក្រុមលោក*ញឹក ប៊ុនឆៃ* នេះ គឺប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* ឱ្យតំណែងតែមន្ត្រីណាដែលគាំទ្រគាត់ ពិសេសមន្ត្រីណា ដែលហ៊ាននិយាយការពិត នៅក្នុងសង្គមខ្មែរនោះ នឹងមិនត្រូវប្រមុខរដ្ឋាភិបាល អោយតំណែងនៅក្នុងរដ្ឋាភិបាលថ្មីទេ ។

អ្នកចាស់ទុំហ៊្វុនស៊ិនប៊ិច បានបន្តទៀតថា លោក*ហ៊ុន សែន* ប្រើយុទ្ធសាស្ត្រ បំផ្លាញគណបក្សហ៊្វុនស៊ិនប៊ិច នាពេលចុងក្រោយនេះ គឺធ្វើយ៉ាងណា ឱ្យសម្តេចក្រុមព្រះមកដឹកនាំហ៊្វុនស៊ិនប៊ិច គឺយុទ្ធសាស្ត្ររបស់ប្រមុខរដ្ឋាភិបាល ចង់ឱ្យអ្នកចាស់ទុំ និងមេទ័ពអតីតអ្នកតស៊ូដើរចេញពីហ៊្វុនស៊ិនប៊ិចទៀត ទៅចុះចូលគណបក្សប្រជាជនទាំងអស់ បើសិនជាជម្រុញអោយសម្តេចក្រុមព្រះទៅដឹកនាំហ៊្វុនស៊ិនប៊ិច បានជោគជ័យទៀតនោះ ។

អ្នកចាស់ទុំហ៊្វុនស៊ិនប៊ិច បានបន្តទៀតថា ហ៊្វុនស៊ិនប៊ិចសព្វថ្ងៃ វាដូចជារបស់លោក*ហ៊ុន សែន* ដូច្នេះឯង ពីព្រោះការធ្វើអ្វី ចង់តែងតាំងអ្នកណាអោយមានតំណែង នៅក្នុងរាជរដ្ឋាភិបាលថ្មី ឬចង់រួបរួម ឬមិនរួប គ្នាជាមួយសម្តេចក្រុមព្រះវិញនោះ សុទ្ធតែរៀបចំ និងស្នើឡើងដោយលោក*ហ៊ុន សែន* ទាំងអស់ ។ ដូច្នេះហ៊្វុនស៊ិនប៊ិច ដែលជាស្នាព្រះហស្ថ របស់អង្គសម្តេចឪនោះ កំពុងតែទទួលរងនូវការបំផ្លាញ ឱ្យរលាយជាអហោសិកម្មតែម្តងហើយ បើសិនជា មេដឹកនាំហ៊្វុនស៊ិនប៊ិច មិនប្រុងប្រយ័ត្នទេនោះ ៕

**តមកពីទំព័រ១ ឃ**

ស្រាវជ្រាវជាន់ខ្ពស់ នៃគណៈកម្មការសិទ្ធិមនុស្សអាស៊ីដែលមានមូលដ្ឋានធំនៅទីក្រុងហុងកុង បានធ្វើការអធិប្បាយថា ដោយសារតែគណបក្សប្រជាជនបានអាសនៈសភាដ៏ច្រើនលើសលប់ហួសពីច្បាប់រដ្ឋធម្មនុញ្ញកំណត់នោះ ដូច្នេះវាពុំមែនជាការចាំបាច់អ្វីដើម្បីនឹងរៀបចំការបោះឆ្នោតកញ្ចប់ជ្រើសតាំងនាយករដ្ឋមន្ត្រី ភ្ជាប់ជាមួយនឹងការជ្រើសរើសថ្នាក់ដឹកនាំសភាជាតិអាណត្តិទី៤នោះទេ។

លោកបណ្ឌិតបានអធិប្បាយយ៉ាងនេះថា "*មិនចាំបាច់ប្រើប្រាស់រដ្ឋធម្មនុញ្ញបន្ថែមនោះទេ។ គេប្រើយ៉ាងនេះទាល់តែធ្វើមិនចេញ ហើយមានឧបសគ្គខ្លាំងទើបបានគេងាកទៅប្រើរដ្ឋធម្មនុញ្ញបន្ថែមដែលមានការបោះឆ្នោតកញ្ចប់នោះ* "។

លោកបានបន្តអធិប្បាយថា "*នេះបង្ហាញថា គណបក្សឈ្នះឆ្នោតច្រើនហើយ ហើយប្រើប្រាស់វិធីបោះឆ្នោតកញ្ចប់បែបនេះអាចនឹងនាំឱ្យមានការកាត់យល់បានថានឹងមានបញ្ហាផ្ទៃក្នុងក្នុងជួរគណបក្សឈ្នះឆ្នោត* "។

បញ្ហាផ្ទៃក្នុង នៃគណបក្សប្រជាជនត្រូវគេជឿថាបានកើតមានជុំវិញជម្លោះប្រជែងដណ្តើមអំណាចគ្នារវាងមន្ត្រីសែខាងលោក*ហ៊ុន សែន*ប្រទាញប្រទង់ និងសែខាងលោកប្រធានបក្ស*ជាស៊ីម* ។ ជម្លោះបែបនេះតែងតែបានកើតមាននៅក្រោយការបោះឆ្នោតបើទោះបីជាគណបក្សអាចបានសម្រេចបំណងក្នុងការរាំងខ្ទប់បញ្ហាមិនឱ្យលេចធ្លាយជាសាធារណៈ ដែលនាំឱ្យបាក់មុខមាត់របស់ខ្លួនដូចកាលអាណត្តិមុនៗនោះក៏ដោយ ។

នៅក្រោយការបោះឆ្នោតខែឧសភា ១៩៩៣ ដែលគណបក្សប្រជាជនបានចាញ់ឆ្នោតរហូតដល់ប្រើប្រាស់កម្លាំងអាវុធបំបែកខេត្តបីនៅខាងកើតទន្លេមេគង្គជាតំបន់អបគមន៍ដើម្បីតថ្លៃរកអំណាចនោះ ជម្លោះច្រណែនគ្នាផ្ទៃក្នុងគណបក្សនេះក៏បានកើតមានឡើងដែរ ។ ជម្លោះនោះក៏ត្រូវបានលេចធ្លាយជាសាធារណៈឱ្យដឹងអំពីការច្រណែនគ្នាក្នុងជួរតំណែងក្នុងរដ្ឋាភិបាល ដោយសារតែផែនការធ្វើរដ្ឋប្រហារមិនបានសម្រេចក្នុងឆ្នាំ១៩៩៤។ ហើយក៏មានការជម្រុញឱ្យស៊ើបអង្កេតរហូតដល់ដំណាក់កាលមួយប្រធានគណបក្សប្រជាជនលោក *ជា ស៊ីម* បានចេញបញ្ជាឱ្យលោក*ហ៊ុន សែន* បញ្ឈប់ការស្រាវជ្រាវនៅពេលដែលមានលេចពន្លឺខ្លះ តាមប្រភពផ្ទៃក្នុងគណបក្សប្រជាជនថា ឃើញមានការសង្ស័យលើការទាក់ទិននឹងលោក *ស ខេង* ឬមនុស្សគណបក្សប្រជាជនដទៃទៀត បន្ទាប់ពីលោក *ស៊ិន សុង* និងលោក *ស៊ិន សេន* បានត្រូវចាប់ខ្លួន។

ហើយជម្លោះនៃការដណ្តើមអំណាចឥទ្ធិពលស្រវាតំណែងតួនាទីក្នុងរដ្ឋាភិបាលបានកើតមានឡើង ដូចស្តែងចេញឱ្យឃើញនូវកម្លាំងអង្គរក្សរបស់លោក *ហ៊ុន សែន* រួមជាមួយកម្លាំងប៉ូលិសរបស់លោក *ហុក ឡងឌី* បានទៅហ៊ុំព័ទ្ធផ្ទះប្រធានគណបក្ស និងផ្ទះអគ្គមេបញ្ជាការកងទ័ពជាតិ ជាមនុស្សខាងប្រធានបក្សក្នុងអំឡុងខែកក្កដាឆ្នាំ២០០៤។ កាលនោះប្រធានគណបក្សប្រជាជនលោក *ជា ស៊ីម* បានត្រូវគេជម្លៀសចេញទៅទុកនៅទីក្រុងបាងកកអស់រយៈពេលច្រើនសប្តាហ៍ មុននឹងអនុញ្ញាតឱ្យចូលមកកម្ពុជាវិញ។

ជាមួយគ្នានោះពួកអ្នកការទូតបានដកស្រង់ប្រភពផ្ទៃក្នុងគណបក្សប្រជាជនប្រាប់កាសែតបរទេសថាជម្លោះដណ្តើមអំណាចតំណែងផ្ទៃក្នុងគណបក្សប្រជាជន សែខាងលោក *ហ៊ុន សែន* អនុប្រធានបក្សជាអ្នកឈ្នះ។

លោក *ជា ស៊ីម* ប្រធានគណបក្សកាលនោះត្រូវបានកាសែតបរទេសដកស្រង់ប្រភពផ្ទៃក្នុងគណបក្សប្រជាជនមកចុះផ្សាយអំពីការដែលគាត់បានទាមទារយកតំណែងខ្លះពីក្រុមសែលោក *ហ៊ុន សែន* ដូចជាក្រសួងធនធានទឹក ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម ព្រមទាំងទាមទារឱ្យអនុប្រធានគណបក្សប្រជាជនគឺលោក*ហ៊ុន សែន* កាត់បន្ថយអំណាចស្អេកស្កះ របស់លោក *សុខ អាន* នៅក្នុងរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរជាតិនានា។ ប៉ុន្តែលោក*ជា ស៊ីម* ប្រធានបក្សជាអ្នកចាញ់នៅក្នុងការប្រជែងអំណាចផ្ទៃក្នុងគណបក្សប្រជាជននោះ។

ហើយនេះនៅតែជាស្រមោលនៃគំរូលងបន្លាចអារម្មណ៍របស់លោក *ហ៊ុន សែន* មកដល់បច្ចុប្បន្ន សូម្បីតែគណបក្សប្រជាជនត្រូវបានគ.ជ.បជាឧបករណ៍របស់ខ្លួនប្រកាសថាជាអ្នកឈ្នះបានអាសនៈសភាដល់ទៅ៩០ ដែលលើសពីចំនួន១ភាគ៣ទៅទៀត ហើយដែលអាចបង្កើតរដ្ឋាភិបាលបានដោយខ្លួនឯងនោះក៏ដោយ។

គម្រោងនៃការទាមទារដោយគណបក្សប្រជាជនខ្លួនឯងជាពិសេសខាងសែលោក *ហ៊ុន សែន* ឱ្យមានការបោះឆ្នោតកញ្ចប់ជ្រើសតាំងរូបគាត់ជានាយករដ្ឋមន្ត្រី តំណាលពេលនិងលើកបញ្ជីជាមួយគ្នានឹងការបោះឆ្នោតជ្រើសរើសប្រធាននិងអនុប្រធានរបស់សភាជាតិអាណត្តិទី៤នេះ ក៏ជារូបភាពនៃការបញ្ជាក់ឱ្យឃើញនូវការមិនទុកចិត្តគ្នាក្នុងផ្ទៃគណបក្សប្រជាជន។

កាលប៉ុន្មានថ្ងៃមុននេះ លោក *ខៀវ កាញារីទ្ធ* រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលជាអ្នកនាំពាក្យរដ្ឋាភិបាលផង និងរបស់គណបក្សប្រជាជនផងនោះបានប្រាប់អ្នកកាសែតនៅឯសន្និសីទកាសែតមួយថា នឹងមានការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងតំណែងនាយករដ្ឋមន្ត្រីសម្រាប់លោក *ហ៊ុន សែន* ជាមួយគ្នានឹងតំណែងថ្នាក់ដឹកនាំសភាជាតិ។ គាត់បានពន្យល់ថា នីតិវិធីនេះដើម្បីធ្វើឱ្យមានការងាយស្រួលនិងដំណើរការរលូនទៅនៃការជ្រើសតាំងថ្នាក់ដឹកនាំអង្គការនីតិប្រតិបត្តិ រួមជាមួយនិងអង្គការនីតិបញ្ញត្តិ។

មន្ត្រីជាន់ខ្ពស់រូបនេះរបស់រដ្ឋាភិបាលគណបក្សប្រជាជនបានពន្យល់ផងដែរថា ដោយសារតែមានបញ្ហាកាលពីអាណត្តិមុនៗហើយក៏មានការប្រើប្រាស់នីតិវិធីបោះឆ្នោតកញ្ចប់ទៅឃើញស្រួល ក៏គេជ្រើសរើសយកវិធីនេះមកប្រើប្រាស់ទៀតដើម្បីសម្រួលដល់ការងារ។

ជាមួយគ្នានេះដែរ អ្នកនយោបាយជាន់ខ្ពស់គណបក្សប្រជាជនម្នាក់លោក *ជាម យៀប* បាននិយាយអំពីហេតុផល ដែលដោយសារមានការពិបាកខ្លាំង ដែលទំនងជាការនិយាយដល់បញ្ហាផ្ទៃក្នុងគណបក្សប្រជាជនរឿងប្រជែងអំណាចគ្នានោះហើយ ទើបតម្រូវឱ្យមានការបោះឆ្នោតជាកញ្ចប់នៅអាណត្តិនេះទៀត បើទោះបីជាគណបក្សប្រជាជនជាអ្នកឈ្នះបានចំនួនកៅអីសភាដល់ទៅ៩០តែឯងនោះ។

លោក *ជាម យៀប* ដែលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សប្រជាជនបាននិយាយយ៉ាងនេះថា "*ដោយសារតែមានផលលំបាកខ្លះ នៅពេលប្រជុំសភាដំបូង* " ដូច្នេះក៏មានការសម្រេចជ្រើសរើសវិធីបោះឆ្នោតជាកញ្ចប់ដើម្បីសម្រួលដល់ការងារ។

គាត់បានបដិសេធនូវព័ត៌មានដែលលេចឮឡើងថា មានបញ្ហាខ្វែងគំនិតគ្នាក្នុងផ្ទៃគណបក្សប្រជាជន ។មន្ត្រីគណបក្សប្រជាជនរូបនេះបាននិយាយថា "*គ្មានបញ្ហាផ្ទៃក្នុងគណបក្សប្រជាជននោះទេ* "។

បើទោះបីជាយ៉ាងនេះក៏ដោយក៏ពួកអ្នកសង្កេតការណ៍និយាយថាគណបក្សប្រជាជនជាពិសេសសែខាងលោក *ហ៊ុន សែន* អនុប្រធានបក្ស ពិតជាមានហេតុផលត្រូវខ្វល់បារម្ភថា បើពុំមានការបោះឆ្នោតកញ្ចប់ជ្រើសតាំងរូបគាត់ឱ្យជាប់ជានាយករដ្ឋមន្ត្រីតំណាលគ្នានឹងការជ្រើសរើសប្រធានម្នាក់ និងអនុប្រធានពីរនាក់នៃសភាជាតិអាណត្តិទី៤ទេ នោះពួកគាត់មិនទុកចិត្តលើសែខាងលោក *ជា ស៊ីម* ។ ហើយវាដូចជាពុំមានអ្វីអាចពន្យល់ឱ្យសមហេតុផលបាន ក្រៅពីថាលោក*ហ៊ុន សែន* ភ័យខ្លាចមានការបោះឆ្នោតជ្រើសតាំងបេក្ខជននាយករដ្ឋមន្ត្រីថ្មីពីគណបក្សប្រជាជនជំនួសរូបគាត់ ប្រសិនបើពុំមានការបោះឆ្នោតកញ្ចប់ជ្រើសតាំងនាយករដ្ឋមន្ត្រីតំណាលគ្នានឹងការជ្រើសតាំងប្រធាន និងអនុប្រធានរបស់សភាជាតិនោះ៕

**តមកពីទំព័រ១ ខ**

ពាននៅភាគខាងលិច ។ បទបញ្ជា បែបមិនច្បាស់លាស់នេះ បានធ្វើឡើង នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ប្រចាំសប្តាហ៍នៅទីស្តីការក្រសួងបណ្តោះអាសន្ន កាលពីព្រឹកថ្ងៃទី១២ ខែកញ្ញា ២០០៨ ។

សមាជិកគណៈរដ្ឋមន្ត្រីម្នាក់ អតីតថ្នាក់ដឹកនាំគណបក្សហ៊្វុនស៊ិនប៊ិច ដែលបានចុះចូលគណបក្សប្រជាជន កាលពីមុនបោះឆ្នោត ហើយបានចូលរួមប្រជុំនៅទីស្តីការក្រសួង កាលពីថ្ងៃសុក្របានអោយដឹងថា លោក*ហ៊ុន សែន* បាននិយាយនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ដែលជិតផុតអាណត្តិនិងគ្មាននៅក្នុងរបៀបវារៈ ដៀមដាមថា កងពលតូចង៧០ ដែលជាអង្គភាពកងការពារអ្នកធំ (ហ៊ុន សែន, ជា ស៊ីម និងហេង សំរិន) នោះ មានខ្លះជាមនុស្ស គ្មានសមត្ថភាពទាល់តែសោះ និងថាពួកអស់លោក គួរតែនាំគ្នាចូលសាលាហ្វឹកហ្វឺនយោធា ជាបន្ទាន់ ដើម្បីទៅតំបន់ប្រាសាទព្រះវិហារ ។ លោក*ហ៊ុន សែន* ក៏បានព្រលយ ពាក្យដៀមដាមឱ្យលោក*ជា ស៊ីម* ប្រធានគណបក្សប្រជាជន និងប្រធានកិត្តិយសលោក*ហេង សំរិន* ដោយមិនចំឈ្មោះផងដែរ ដែលចេះតែតែងតាំង ទីប្រឹក្សាដ៏ច្រើនស្អេកស្កះ ។

សមាជិក គណៈរដ្ឋមន្ត្រីរូបនោះ បានប្រាប់*ខ្មែរម្ចាស់ស្រុក* ក្នុងលក្ខខណ្ឌ សុំមិនឱ្យបញ្ចេញអត្តសញ្ញាណ តាមសម្តីលោក*ហ៊ុន សែន* ថា អស់លោក កុំអាងតែមានសិទ្ធិ ធ្វើលិខិតស្នើសុំព្រះរាជក្រឹត្យតែងតាំង ចេះតែធ្វើគ្មានសណ្តាប់ធ្នាប់ និងធ្វើច្រើនហួសហេតុពេក ពីព្រោះអស់លោក ល្មមស្កប់ស្កល់ខ្លះហើយ ។

សម្តីដៀមដាម របស់លោក*ហ៊ុន សែន* នេះ បានធ្វើអោយរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ខ្សែលោក*ជា ស៊ីម* និងលោក*ហេង សំរិន* ខ្លះមិនសប្បាយចិត្តទេ ពីព្រោះទីប្រឹក្សាលោក*ជា ស៊ីម* និងលោក*ហេង សំរិន* រួមគ្នា មិនស្មើនឹងទីប្រឹក្សា លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ម្នាក់ផងជាពិសេស លោក*ហ៊ុន សែន* បានស្នើព្រះមហាក្សត្រ តែងតាំងអភិបាល អភិបាលរង ខេត្តក្រុង មន្ត្រីប៉ូលិស យោធា និងនៅតាមមន្ទីរ ស្ថាប័នមួយចំនួនជាទីប្រឹក្សារបស់គាត់ស្អេកស្កះទៅហើយនោះ ។ ជាងនេះទៅទៀត លោក*ហ៊ុន សែន* បានតែងតាំងអ្នកលក់ឧត្តមគតិ ពីគណបក្សសម រង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៊ិច មួយដំបរស្វាជាទីប្រឹក្សារដ្ឋាភិបាល កាលពីមុនបោះឆ្នោតទៀតផង ។

ទោះយ៉ាងណា មានមន្ត្រីខ្លះនៃគណបក្សប្រជាជន បានគាំទ្រការលើកឡើង របស់លោក*ហ៊ុន សែន* នៅក្នុងកិច្ចប្រជុំនៃគណៈរដ្ឋមន្ត្រី ជិតផុតអាណត្តិ កាលពីថ្ងៃសុក្រ សប្តាហ៍មុនចំពោះដែលថា អនុប្រធានអង្គភាពអង្គរក្សង-៧០ ជាង២០នាក់នោះ ដែលខ្លះបានងារ ជាឧត្តមសេនីយ៍ ដោយមិនធ្លាប់បានចូលសាលាយោធាឬឡើងស័ក្តិតាមស្នាដៃ ពីស័ក្តិ១,ស័ក្តិ២, ស័ក្តិ៣, ស័ក្តិ៤, ស័ក្តិ៤,៥ និងស័ក្តិ៥អីទេ គឺពួកអស់នេះ

**តនៅទំព័រ៣ ខ**

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៣**
Tel: 012 850 690 / 017 360 678 , Fax: 023 987 411

### តមកពីទំព័រ១ ខ

នៅស្រុកបន្ទាយអំពិល នៃខេត្តឧត្តរមានជ័យនិងទឹកដីខ្មែរតាមតំបន់ព្រំដែនដទៃទៀតនោះ ក៏ដោយសារតែជាផលវិបាកនៃនយោបាយអំណួតរបស់រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន ចាញ់បោកសៀម ។

រឿងរដ្ឋាភិបាល ហ៊ុន សែន ចាញ់បោកសៀមនេះមានដំណើរដើមទងតាំងតែពីការដែលហ៊ុន សែន បានវក់ដៃចុះហត្ថលេខាជាមួយនាយករដ្ឋមន្ត្រីសៀម ថាក់ស៊ីន ស៊ីណាវ៉ាត្រា នៅឆ្នាំ២០០០រួចមកនៅក្នុងឆ្នាំ២០០៣ បង្កើតអ្វីដែលគេហៅថា ភាពមិនច្បាស់លាស់នៃខ្សែបន្ទាត់ព្រំដែនជាលេសផ្តល់ឱ្យសៀមបង្កើតពាក្យតំបន់សដើម្បីលើកទ័ពចូលកាន់កាប់ ។

នោះជារឿងមានលំដាប់ជាហូរហែ ដែលប្រធានគណៈកម្មការព្រំដែនកម្ពុជាមានមូលដ្ឋាននៅប្រទេសបារាំងបានហៅអនុស្សារណៈដែល ហ៊ុន សែន បានស៊ីញ៉េជាមួយនាយករដ្ឋមន្ត្រីសៀមឆ្នាំ២០០០ និង២០០៣ នោះហើយដែលធ្វើឱ្យសៀមមានលេសបង្កើតរបស់ដែលហៅថាតំបន់ស និងលើកគ្នាចូលកាន់កាប់ដីខ្មែរនោះ ។

ហើយតឹកតាងបង្ហាញឱ្យដឹងយ៉ាងច្បាស់ថែមទៀតថា រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន បានចាញ់បោកសៀម គឺនៅក្នុងអំឡុងខែឧសភា និងខែមិថុនា ក៏ដូចជាខែកក្កដាកន្លងទៅនេះ ។ កាលនោះមានជំនួបថ្នាក់មន្ត្រីជាន់ខ្ពស់ សុខ អាន តំណាងរដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន និងរដ្ឋមន្ត្រីការបរទេសសៀម នុបផាដុន ប៉ាតាម៉ា នៅទីស្នាក់ការអង្គការយូណេស្កូ ក្នុងទីក្រុងប៉ារីស ដែលជំនួបនោះបានប្រព្រឹត្តទៅក្នុងរយៈពេល១០ម៉ោង ទីបំផុតសៀមបានទាមទារឱ្យរដ្ឋាភិបាល ហ៊ុន សែន ព្រមគូសផែនទីបរិវេណប្រាសាទព្រះវិហារជាថ្មី និងសេចក្តីថ្លែងអះអាងអំពីបំណងកម្ពុជាដាក់ប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

ពេលត្រឡប់មកដល់កម្ពុជាវិញ ស្រាប់តែ ហ៊ុន សែន បានប្រើ សុខ អាន ឱ្យគូសផែនទីបរិវេណប្រាសាទព្រះវិហារជាថ្មីជាមួយសេចក្តីបញ្ជាក់ថាកម្ពុជាសុំដាក់តែតួប្រាសាទព្រះវិហារ និងដីជុំវិញប្រាសាទ៣០ម៉ែត្រទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។ ក្នុងអំឡុងខែមិថុនា ពេលដែលរដ្ឋាភិបាល ហ៊ុន សែន បានបញ្ជូនឯកសារទៅឱ្យសៀមនោះ សៀមក៏បានយល់ព្រមតាមសំណើរបស់កម្ពុជា ហើយគណៈកម្មការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ បានធ្វើកិច្ចប្រជុំនៅទីក្រុងកេបិច ប្រទេសកាណាដា នៅថ្ងៃទី៧ ខែកក្កដា ដាក់បញ្ចូលប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោកទៅ ។

ដោយសារតែគូសផែនទីបរិវេណប្រាសាទព្រះវិហារឱ្យសៀមពិនិត្យនោះហើយ ដែលរដ្ឋាភិបាល ហ៊ុន សែន បានធ្វើអ្វីៗបង្ហាញថា ខ្លួនបានធ្លាក់ទៅក្នុងអន្ទាក់នយោបាយរបស់សៀមទាំងស្រុង។ មែន នៅថ្ងៃ១៥ កក្កដា តែមួយថ្ងៃក្រោយពី សុខ អាន បានប្រើឈ្មោះប្រាសាទព្រះវិហារបើកយុទ្ធនាការស្វែងរកសន្លឹកឆ្នោតឱ្យគណបក្សប្រជាជន ហ៊ុន សែន នោះ សៀមបានលើកទាហានចូលមកកាន់កាប់វត្តខ្មែរកែវសិក្ខាគីរីស្វារៈ នៅតំបន់ប្រាសាទព្រះវិហារនៃទឹកដីកម្ពុជា សូម្បីតែសៀមដឹងថាសាលក្រមតុលាការអន្តរជាតិក្រុងឡាអេឆ្នាំ១៩៦២ ចេញសេចក្តីថ្លែងយ៉ាងច្បាស់ថានោះគឺជាតំបន់ទឹកដីខ្មែរក៏ដោយ ។

ប៉ុណ្ណឹងហើយរដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន មិនទាន់ភ្ញាក់ដឹងខ្លួននោះទេ រួចបែរជាធ្វើអ្វីៗតាមតែសៀមទាមទាររហូត ជាពិសេសការចរចាទ្វេភាគីផ្នែកកិច្ចការទូតមិនឱ្យមានភាគីអន្តរជាតិជួយស្តាប់ដឹងឮឡើយ ។

ហ្នឹងហើយដែលធ្វើឱ្យសៀមកាន់តែបានចិត្តហើយក៏ប្រើយុទ្ធវិធីចរចាទ្វេភាគីផ្នែកការទូតបិទបាំងសកម្មភាពផ្នែកយោធាកាន់កាប់ដីខ្មែររាលដាលដល់តំបន់នានាតាមខ្សែបន្ទាត់ព្រំដែនខ្មែរសៀមនោះ ។

អ្វីដែលអាចឱ្យមើលយ៉ាងច្បាស់ថា រដ្ឋាភិបាលគណបក្សប្រជាជនហ៊ុនសែនបានបណ្តោយខ្លួនឱ្យចាញ់បោកសៀមម្តងហើយម្តងទៀត ទំនងជាមានអ្វីដូចជាគេសង្ស័យថាជាកិច្ចសន្យាសម្ងាត់រវាងហ៊ុន សែនជាមួយ ថាក់ស៊ីន អ្នកដែលមានឥទ្ធិពលលើនាយករដ្ឋមន្ត្រីសៀម សាម៉ាក់ ស៊ុនដារ៉ាវេតទើបចុះចេញពីតំណែងនោះ ក៏គឺជាមូលហេតុនៃការដែលកម្ពុជាធ្វើតែតាមការទាមទាររបស់សៀម។

នោះគឺគេនៅចាំយ៉ាងច្បាស់ណាស់ថា កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ រយៈពេល៦ថ្ងៃក្រោយពីទាហានសៀមលើកគ្នាចូលកាន់កាប់វត្តខ្មែរនោះ កម្ពុជាក៏បានធ្វើបណ្តឹងតវ៉ាទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ហើយនៅថ្ងៃនោះ សៀមក៏បាន ទាក់ទងមក ហ៊ុន សែន សុំឱ្យមានការជួបប្រជុំថ្នាក់ខ្ពស់ នៃអ្នកគ្រប់គ្រងផ្នែកយោធានៅក្រុងអារញ្ញនៃទឹកដីប្រទេសសៀម។

នៅជំនួបនោះសៀមបានទាមទារលក្ខខណ្ឌយ៉ាងច្រើនរាប់ទាំងការឱ្យ ហ៊ុន សែនព្រមបែងចែកប្រយោជន៍ស្មើរតែពាក់កណ្តាលដែលបានពីវិស័យទេសចរណ៍នៅប្រាសាទព្រះវិហារទៅឱ្យសៀមក្នុងបណ្តាលក្ខខណ្ឌផ្សេងៗដែលមានការដកទាហានខ្មែរចេញពីដីខ្មែរផងដែរនោះ។

រឿងនេះគេមើលឃើញថាហ៊ុន សែនបានចាញ់ល្បិចសៀមពីព្រោះដូច ហោ ណាំហុង បាននិយាយក្រោយពីការជួបថ្នាក់រដ្ឋមន្ត្រីការបរទេសខ្មែរ-សៀមថ្ងៃទី១៨-១៩ខែសីហា២០០៨នៅហួរហ៊ីនទឹកដីសៀម។ ក្រោយជំនួបនោះ ហោណាំហុង បាននិយាយអួតអំពីការដែលកម្ពុជាស្ម័គ្រចិត្តដកបណ្តឹងពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផង និងប្រកាសជាឯតោភាគីមិនបាច់សៀមទាមទារឡើយក្នុងការដកទាហានខ្មែរចេញពីប្រាសាទព្រះវិហារ ដែលសៀមទទួលស្គាល់ថា ជារបស់ខ្មែរស្រាប់ផងនោះ។ រដ្ឋាភិបាល ហ៊ុន សែនបានចាញ់ល្បិចសៀមនេះ ព្រោះគិតថា បែបនេះគឺជាការអង្វរស្ទាបដៃស្ទាបជើងយកចិត្តសៀមឱ្យព្រមដកទាហានក្រោយខ្មែរចេញពីវត្តខ្មែរនៅតំបន់ប្រាសាទព្រះវិហារ។

ការគួរឱ្យកត់សម្គាល់ដ៏សំខាន់មួយនោះ គឺនៅក្រោយពីបានការសន្យា និងការលួងលោមរបស់សៀមនាជំនួបក្រុងហួរហ៊ីនទឹកដីសៀមកាលពីថ្ងៃទី១៨-១៩ ខែសីហា ឆ្នាំ២០០៨ ហោ ណាំហុង ចេញទៅវិញក៏បានប្រកាសថាការចរចាខ្មែរសៀមថ្នាក់ខ្ពស់ប្រដូចបាននឹងល្បឿននៃរូឡូកិនថ្មល់ដ៏យឺតៗសម្រាប់ជានីតិវិធីនៃការចរចា ក្នុងការរកដំណោះស្រាយបញ្ចប់បញ្ហាប្រឈមមុខដាក់គ្នាផ្នែកយោធានៅតំបន់ទល់ដែន។

ទន្ទឹមនឹងនេះ ហោ ណាំហុង ក៏បាននិយាយអំពីការដែលភាគីសង្ខាងព្រមព្រៀងគ្នាថាឱ្យមានជំនួបថ្នាក់រដ្ឋមន្ត្រីការបរទេសនៅថ្ងៃទី២៩ ខែសីហា មួយលើកទៀត គឺជាជំនួបដែលគេបានលុបចោលទៅវិញដោយនៅប្រទេសសៀមមានភាពវឹកវរផ្នែកនយោបាយ ។

ភាពចលនាចលនៃនយោបាយនៅប្រទេសសៀមបាននាំមកដល់ការធ្លាក់ពីតំណែងនៃនាយករដ្ឋមន្ត្រីសៀម សាម៉ាក់ ស៊ុនដារ៉ាវេត បន្ថែមពីលើការដែលសៀមបានផលចំណេញពីការលើកទាហានចូលមកក្នុងដីខ្មែរ ហើយរដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន មិនហ៊ានប្រើអ្វីដើម្បីរារាំងទាហានសៀមឈ្លានពាននេះទេ។

អស់ទាំងហ្នឹងក៏រឹតតែបង្ហាញឱ្យគេឯងដឹងថា គណបក្សប្រជាជន ហ៊ុន សែន ប្រើឈ្មោះរដ្ឋាភិបាលកម្ពុជាមិនត្រឹមតែបានចាញ់បោកល្បិចការទូតនយោបាយសៀម ហើយមិនហ៊ានធ្វើអ្វីទាហានសៀមចូលឈ្លានពានកាន់កាប់ទឹកដីកម្ពុជានោះទេ ប៉ុន្តែរដ្ឋាភិបាលគណបក្សប្រជាជន នៃពួក ហ៊ុន សែន បានទាំងចាញ់បោកខ្លួនឯងទៅទៀត។

គេដឹងថា រដ្ឋាភិបាល ហ៊ុន សែនចាញ់បោកខ្លួនឯងនៅត្រង់ថា ថ្មីៗនេះ ហ៊ុន សែន បានប្រកាសថា កម្ពុជាអស់ការអត់ធ្មត់ហើយក៏រៀបចំឯកសារចាប់ប្តឹងតវ៉ាទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬដាក់បណ្តឹងទៅតុលាការអន្តរជាតិវិញ៕

### តមកពីទំព័រ១ គ

នឹងភាពវឹកវរ របស់ប្រទេសសៀម ដែលអាចនាំទៅរំខាននៃការធ្វើម្ចាស់ផ្ទះប្រជុំអាស៊ានដែលគ្រោងនឹងធ្វើនៅថ្ងៃទី២១ កញ្ញា ២០០៨ ខាងមុខនេះ ។

សេចក្តីថ្លែងការណ៍ បានធ្វើឡើងតែប៉ុន្មានម៉ោង បន្ទាប់ពីកាសែតបាងកកប៉ុស្តិ៍ ចុះផ្សាយស្រង់សម្តីលោកហ៊ុនសែន ខុសថា "នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨កាសែត បាងកកប៉ុស្តិ៍របស់ថៃ បានចេញផ្សាយ នូវអត្ថបទមួយ ដោយបានលើកឡើងថា សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានលើកថាប្រទេសថៃគួរតែពិចារណាស្ម័គ្រចិត្តបោះបង់ចោលជាបណ្តោះអាសន្ននូវតួនាទីជាប្រធាន [ សមាគម ប្រជាជាតិអាស៊ីអគ្នេយ៍ ហៅកាត់ថា អាស៊ាន ]... ហើយថៃគួរតែផ្ទេរតួនាទីប្រធានេះ ទៅប្រទេសសិង្ហបុរី ឬប្រទេសវៀតណាមវិញ, ហើយកាសែត បាងកកប៉ុស្តិ៍ បានអត្ថាធិប្បាយថា ការធ្វើអត្ថាធិប្បាយ របស់សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន នេះជាការមិនធម្មតា ដោយថាជាធម្មតាសមាជិកអាស៊ាន រមែងចៀសវាងមិនធ្វើអត្ថាធិប្បាយលើបញ្ហាផ្ទៃក្នុងរបស់សមាជិកអាស៊ានឯទៀតឡើយ " ។

សេចក្តីប្រកាសព័ត៌មានបានបន្តថា អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការបញ្ជាក់ថា នៅក្នុងបទសម្ភាសន៍ ជាមួយអ្នកកាសែត នៅក្រោយពីពេលជួបជាមួយ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេស អាមេរិកនិងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយរបស់សហរដ្ឋអាមេរិកមក លោក ហ៊ុន សែន មិនដែលប្រើពាក្យ "គួរតែ" ឬ "ត្រូវតែ" ឬពាក្យអត្ថាធិប្បាយណាមួយ ដែលប៉ះពាល់ ដល់បញ្ហាតួនាទី ជាប្រធានអាស៊ាន របស់ប្រទេសថៃនោះឡើយ ។ លោកហ៊ុន សែន គ្រាន់តែលើកពីកង្វល់ពីលទ្ធភាព ដែលអាចកើតមានជាយថាហេតុ ដែលការប្រជុំកំពូលអាស៊ាន មិនអាចធ្វើទៅបាននៅប្រទេសថៃ ហើយតើគេនឹងទៅធ្វើកិច្ចប្រជុំនៅទីណាបានតែប៉ុណ្ណោះ។ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជាសូមលើកឡើងជាថ្មី នូវគោលជំហរឥតប្រែប្រួល របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគោរពអធិបតេយ្យភាព និងឯករាជ្យរបស់ប្រទេសទាំងអស់ ទោះជានៅក្នុងឬក្រៅអាស៊ានក្តី ។

ជាចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍ បានបញ្ជាក់ថា លោក ហ៊ុន សែន បានបញ្ជាក់ យ៉ាងច្បាស់ក្នុងការផ្តល់បទសម្ភាសន៍កាលពីល្ងាចថ្ងៃទី១៥ ខែកញ្ញា ២០០៨ កន្លងមកនេះហើយថា អ្វីដែលលោក(ហ៊ុនសែន) បានលើកអំពីកង្វល់នេះ មិនមែនទាក់ទិន តែមុខមាត់របស់ប្រទេសថៃប៉ុណ្ណោះទេ តែគឺទាក់ទិន នឹងសមាជិកអាស៊ានទាំងអស់តែប៉ុណ្ណោះ ។ មកដល់បច្ចុប្បន្ននេះបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជា គឺគ្មានអ្វីក្រៅពីចង់ឃើញសភាពការណ៍របស់ប្រទេសថៃ វិលត្រឡប់ទៅរកប្រក្រតីភាពវិញ ដើម្បីធានាសន្តិភាព និងសុខដុមរមនា ក្នុងសង្គមជាតិថៃផង ក្នុងសហគមន៍អាស៊ាននេះផងនោះឡើយ ។

ពាក់ព័ន្ធ នឹងកិច្ចប្រជុំកំពូលអាស៊ាន ដែលគ្រោងនឹងធ្វើនៅប្រទេសសៀមនេះ លោកហ៊ុន សែន បាននិយាយ ហើយត្រូវស្ថានីយ៍ទូរទស្សន៍ក្នុងស្រុក ចុះផ្សាយសម្តីនោះឡើង មានខ្លឹមសារថា "...នាយករដ្ឋមន្ត្រី ក្នុងតំណែងម្នាក់ មិនអាចទាយនូវអនាគតខ្លួនឯងបានផង អីចឹងទេ យើងទាំងអស់គ្នា ឬកង្វល់នៅក្នុងនាម សមាជិកអាស៊ានទាំងអស់គ្នាផង បើអាស៊ានប្រជុំមិនបាននៅប្រទេសថៃ តើត្រូវវិលត្រឡប់ទៅសាំងហ្គាពួរ ឬក៏ត្រូវបង្ហួស ទៅវៀតណាម, ហើយអ្នកទាំងនោះ ប្រហែលជាមិនទាន់បាន ត្រៀមខ្លួនទេ, ដោយសារតែមិនទាន់មានការអះអាងណាមួយ...ហើយខ្ញុំ ក៏មិនទាន់ឮលោកសុរិន្ទ ពិនសុវណ្ណ ដែលជាអគ្គលេខាធិការថ្មីរបស់អាស៊ាន មានការព័ត៌នាយ៉ាងណាទេ, តែបើមានរឿងនៅប្រទេសដទៃ ដូចជាភូមា, សុរិន្ទ ពិនសុវណ្ណ និយាយច្រើនណាស់...។ ក្នុងនាមយើង ជាសមាជិកអាស៊ានម្នាក់ដែរ បើប្រជុំមិនបានតើត្រូវធ្វើម៉េច ។ នេះជាបញ្ហាមួយ ហើយដោយសារតែថៃ ជាប្រធានអាស៊ានផង, ថៃមិនទាន់បានពិគ្រោះជាមួយនរណាទេ ហើយជាសមាជិកចេះតែរង់ចាំ " ។

លោកហ៊ុន សែន ក៏បានអះអាង អំពីភាពអត់ធ្មត់របស់ប្រទេសកម្ពុជា ពាក់ព័ន្ធទៅនឹងការឈ្លានពានរបស់ទាហានឈុតខ្មៅសៀម នៅតាមព្រំដែននៃប្រទេសកម្ពុជាដែរ ។ លោក ហ៊ុន សែន បាននិយាយថា ទាហានឈុតខ្មៅសៀមនោះ ជាចោរទៀតផង នៅពេលដែលប្រជាពលរដ្ឋខ្មែរ បានហៅពួកឈ្លានពានទាំងនោះ ជាចោរឈ្លានពានទឹកដីខ្មែរ ទៅហើយនោះ ។

លោកហ៊ុន សែន បានថ្លែងដូចរបៀបយល់សប្តិថា នឹងរួមដៃគ្នាជាមួយរដ្ឋាភិបាលសៀម ដើម្បីច្បាំងបណ្តេញ ទាហានឈុតខ្មៅសៀម ដែលជាកងការពារ របស់ព្រះមហាក្សត្រសៀម ។

អ្វីដែល ប្រជារាស្ត្រខ្មែរអស់សំណើចនោះ នៅត្រង់ថា ប្រមុខរដ្ឋាភិបាល បារម្ភអំពីកិច្ចប្រជុំកំពូល របស់អាស៊ាននៅប្រទេសសៀមមិនអាចប្រព្រឹត្តទៅបានដោយសារតែមានភាពវឹកវរ ។ ប៉ុន្តែលោកហ៊ុន សែន មិនឆ្ងល់ទេថា ចុះសៀមកំពុងតែវឹកវរយ៉ាងហ្នឹងហើយ ម្តេចក៏ឆ្លៀតឈ្លានពាន ព្រំដែនខ្មែរយ៉ាងគឃ្លើនបានទៀត ។

មតិប្រជាពលរដ្ឋ បានចំអកសម្តីលោកហ៊ុន សែន ថា ព្យាយាមខំអត់ធ្មត់ ជាមួយចោរសៀម ។ ប៉ុន្តែសម្តីនេះគឺគ្រាន់តែជាពាក្យបិទបាំង ការពិតតែប៉ុណ្ណោះ ពីព្រោះលោកហ៊ុន សែន អត់ធ្មត់នេះ មកពីគាត់ខ្លាចចោរសៀម, ហើយលោក ហ៊ុន សែន ខ្លាំងបានតែជាមួយខ្មែរគ្នាឯង ជាពិសេសទាហានលោកហ៊ុន សែន សាហាវខ្លាំងណាស់ ខាងបាញ់ប្រជាពលរដ្ឋប្លន់យកដីធ្លី ដែលប្រការនេះធ្លាប់បានកើតមាន នៅទូទាំងប្រទេសកម្ពុជា ៕

### តមកពីទំព័រ២ ខ

មានអំណាចដុល្លារ ឡើងរហូតដល់ឧត្តមសេនីយ៍តែម្តង ។

មន្ត្រីយោធា ង-៧០ ម្នាក់បានឱ្យដឹងថា ង-៧០ គឺជាកងអង្គរក្សអ្នកធំដែលក្នុងនោះប្រជុំទៅដោយ កងកម្លាំងប្រដាប់អាវុធ មកពីគ្រប់គណបក្ស គឺគណបក្សប្រជាជន គណបក្សហ៊្វុនស៊ិនប៉ិច ។ អនុប្រធានអង្គភាពនេះខ្លះ ក៏ជាប្រធានអង្គរក្សសម្តេចក្រុមព្រះដែរ កាលពីទ្រង់ នៅជាប្រធានរដ្ឋសភា, ហើយក៏មានអនុប្រធានខ្លះ ជាប្រធានអង្គរក្សលោកជា ស៊ីម លោកហេង សំរិន, លោកស ខេង ផងដែរ ។

ប្រភពបានបន្តថា ឧត្តមសេនីយ៍ខ្លះ ជាអនុប្រធាន ង-៧០ នោះ អត់ចេះរបៀបកងទ័ពទេ គឺអ្នកខ្លះ មិនដឹងថា គោរពអ្នកធំនោះ ត្រូវកន្ធែកជើងឆ្វេងឬជើងស្តាំដែរ និងខ្លះទៀត មានងារតែអនុប្រធានមិនសូវដែលមានមុខនៅអង្គភាពឡើយ ។

សមាជិកគណៈរដ្ឋមន្ត្រី ជាអតីត មន្ត្រីហ៊្វុនស៊ិនប៉ិចដដែល បានបន្តទៀតថា អ្នកចូលរួមភាគច្រើន នៅក្នុងកិច្ចប្រជុំបានសំដែងការភ្ញាក់ផ្អើល ទៅនឹងសម្តីលោកហ៊ុន សែន ដែលគួរតែសប្បាយចិត្ត នឹងជ័យជំនះភ្លូកទឹកភ្លូកដីចំពោះការលួចបន្លំសន្លឹកឆ្នោត របស់គណបក្សប្រជាជន ទទួលបានអាសនៈចំនួន៩០នោះ ។ ផ្ទុយទៅវិញលោក ហ៊ុន សែន បានមួម៉ៅក្តៅក្រហាយ ហើយក៏បានធ្វើជាព្រមានថា នឹងប្តឹងចោរសៀមទៅអង្គការសហប្រជាជាតិ ឬក្រុមប្រឹក្សា របស់អង្គការសហប្រជាជាតិទៀតផង ។

ភាពមួម៉ៅ ដែលគេដឹងថាលោកហ៊ុន សែន មិនសប្បាយចិត្ត ទៅនឹងទាហានឈុតខ្មៅសៀមចំនួន១៤៥នាក់ ទើបតែឈ្លានពានប្រាសាទតាក្របីខ្មែរ គឺជាការឈ្លានពាន ចុងក្រោយគេក្នុងចំណោម នៃការឈ្លានពានជាច្រើនកន្លែងនោះ ។

ទោះយ៉ាងណាគេមិនជឿថា លោកហ៊ុន សែន បញ្ជាអោយអនុប្រធាន ង-៧០ ជាង២០នាក់នោះ ចូលសាលាហ្វឹកហ្វឺនកងទ័ពដើម្បីត្រៀមធ្វើសង្គ្រាមជាមួយសៀមទេ, ហើយអនុប្រធាន ង-៧០ ទាំងជាង២០នាក់នោះ ខ្លាំងបានតែ ជាមួយប្រជាពលរដ្ឋខ្មែរស្លូតត្រង់ តែប៉ុណ្ណោះ ពិសេសជាមួយប្រជាពលរដ្ឋ ដែលការពារដីធ្លី ស្រែចំការ និងផ្ទះសំបែងរបស់គាត់ មិនឱ្យអ្នកមានអំណាចនិងអ្នកមានប្រាក់ប្លន់យក ៕

### តមកពីទំព័រ៤ ន

ធិរិទ្ធ ។

បើគិតអំពីរយៈពេលនេះ សាលាក្តីខ្មែរក្រហមត្រូវបានគេរិះគន់កប់ៗមាត់ថា ចាយវាយលុយកាក់អស់មួយគំនរទៅហើយ តែពុំទាន់បានកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមណាម្នាក់តាមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

មជ្ឈដ្ឋានជាទូទៅបានសម្តែងនូវការព្រួយបារម្ភថា អតីតមេដឹកនាំខ្មែរក្រហមមានវ័យកាន់តែចាស់ជរាណាស់ទៅហើយ បើសាលាក្តីខ្មែរក្រហមធ្វើការយឺតយ៉ាវបែបនេះទំនងជាមានការកាត់ទោសគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះក៏អាចថាបានដែរ៕

**តំលៃ ១០០០រៀល**

**សេវាទទួលទិញសម្ភារៈចាស់ៗ**
មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។
-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា
-មានទទួលទិញក្នុងតម្លៃសមរម្យ
-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម
ទំនាក់ទំនងទូរស័ព្ទលេខ : 017 606 125

**ក្រុមហ៊ុនភាពយន្ត ជនបទ**
មានទទួលបញ្ចាំង
ខ្សែភាពយន្តខ្នាតធំ
ក្នុងពិធីផ្សេងៗ
មានពន្លឺច្បាស់
ទំនាក់ទំនងតាមទូរស័ព្ទ
012 66 44 67
015 66 44 67

ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

Tel: 012 850 690 / 017 360 678 , Fax: 023 987 411

តមកពីទំព័រ១ ម

ponte ឧបការី រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក និងក្រុមមេដឹកនាំគណបក្សប្រឆាំង។

ក្នុងនោះលោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ីបាន អះអាងថា "*ប្រទេសអឺរ៉ុប និងសហរដ្ឋអាមេរិកប្រាកដជាមិនព្រងើយកន្តើយចំពោះការជាប់គាំងនយោបាយនៅពេលដែលគណបក្សទាំងពីរមិនចូលរួមប្រជុំសភាលើកដំបូងនាពេលខាងមុខនេះ*"។

លោក*សមរង្ស៊ី* បានបង្ហាញនូវហេតុផលច្បាប់ច្បាស់ៗថា "*ខ្ញុំជឿថា សហរដ្ឋអាមេរិកនឹងរំលឹកថ្នាក់ដឹកនាំប្រទេសកម្ពុជាដែលជាគណបក្សកាន់អំណាចសព្វថ្ងៃដើម្បីស្វែងយល់អំពីគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យនៅពេលដែលគេជួបប្រធានគណបក្សប្រឆាំងដូចខ្ញុំបានលើកឡើងអម្បាញមិញនេះ គឺគេឱ្យតម្លៃទៅគណបក្សប្រឆាំង។ ហើយបើគ្មានគណបក្សប្រឆាំង គឺថ្នាក់ដឹកនាំប្រទេសសព្វថ្ងៃនឹងក្លាយទៅជាជនផ្តាច់ការជិះសេះលែងដៃ ធ្វើអ្វីៗស្រេចតែអំពើចិត្ត ដែលខ្ញុំមើលទៅឃើញខូចខាតផលប្រយោជន៍ប្រទេសជាតិច្រើនណាស់*"។

ទាក់ទិនទៅនឹងសំណើរឱ្យការកែទម្រង់ច្បាប់បោះឆ្នោត និងទាមទារឱ្យផ្តល់តួនាទីដល់បក្សប្រឆាំងបានធ្វើឡើងនៅក្រោយបណ្តឹងទាំងរបស់ក្រុមអ្នកប្រឆាំងទាក់ទងនឹងលទ្ធផលបោះឆ្នោតនាពេលថ្មីៗនេះ។

ជាមួយគ្នានេះដែរលោក*កឹម សុខា* ប្រធានគណបក្សសិទ្ធិមនុស្សបានលើកឡើងថា គណបក្សប្រឆាំងទាំងពីរនៅតែបន្តធ្វើពហិការមិនចូលរួមប្រជុំបើសិនសំណើទាមទារការកែទម្រង់ច្បាប់មួយចំនួនសម្រាប់ការបោះឆ្នោតលើកក្រោយៗដែលត្រូវបដិសេធទៀតនោះ។

លោក *កឹម សុខា* បានបញ្ជាក់បន្ថែមទៀតថា "*គោលដៅរបស់យើងមិនមែនដើម្បីអំណាចទេគឺដើម្បីឱ្យលទ្ធិប្រជាធិបតេយ្យរស់តទៅមុខបានយ៉ាងហោចណាស់ក៏ត្រូវតែដោះស្រាយបញ្ហាពនេះសិនដែរ។ ព្រោះប្រសិនបើយើងអស់ឱ្យមានការបោះឆ្នោតកែលម្អទៅមុខទៀត ហើយការបោះឆ្នោតនៅតែអាក្រក់អញ្ចឹងទៀត គឺប្រជាធិបតេយ្យនៅស្រុកខ្មែរប្រាកដជាអស់ហើយ*"។

គួរបញ្ជាក់ថាចាប់តាំងពីថ្ងៃប្រកាសលទ្ធផលឆ្នោតរហូតមកដល់ពេលនេះ គឺគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សក្នុងដំណើរទៅកាន់ប្រទេសអឺរ៉ុបកាលពីកន្លងមក ដោយបានជួបនឹងសភាអឺរ៉ុប គឺមេដឹកនាំគណបក្សប្រឆាំងទាំងពីរបានដាក់ពាក្យបណ្តឹងដោយចោទប្រកាន់ថា រដ្ឋាភិបាលខ្មែរមិនគោរពកិច្ចព្រមព្រៀងក្រុងប៉ារីស។

នៅក្នុងបណ្តឹងនោះ គណបក្សទាំងពីរបានផ្តល់ភស្តុតាងអំពីការលួចបន្លំសន្លឹកឆ្នោតនិងភាពមិនប្រក្រតីជាច្រើនទៀត។

គួររំលឹកថាកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៨ ក្រុមអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីទាំង២៦រូបបានទូលថ្វាយព្រះមហាក្សត្រខ្មែរតាមរយៈលិខិតមួយច្បាប់ដែលមានខ្លឹមសារដូចខាងក្រោមនេះ :

ទូលព្រះបង្គំ ខ្ញុំអម្ចាស់ទាំងអស់គ្នាជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រអាណត្តិទី៤ នៃគណបក្សសមរង្ស៊ី សូមក្រាបបង្គំដោយសេចក្តីស្វាមីភក្តិ និងគោរពជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតចំពោះព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសូមទូលថ្វាយនូវសេចក្តីសម្រេចចិត្តថា "*នឹងមិនទៅចូលរួមក្នុងសម័យប្រជុំដំបូង នៃរដ្ឋសភានីតិកាលទី៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ វេលាម៉ោង៨:៣០នាទីព្រឹកនោះទេ*" ប៉ុន្តែនឹងចូលរួមប្រជុំនៅពេលក្រោយ។

ការសម្រេចចិត្តរបស់ទូលព្រះបង្គំ ខ្ញុំម្ចាស់ទាំងអស់នេះ ធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរជាច្រើនលាននាក់ ដែលជាអ្នកបានបោះឆ្នោតគាំទ្រដល់គណបក្សសមរង្ស៊ីកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅផង និងក្នុងនាមប្រជារាស្ត្រខ្មែរដែលត្រូវបានគេរំលោភសិទ្ធិនៃការបោះឆ្នោតតាមរយៈការលុបបំបាត់ឈ្មោះពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ការលួចបោះឆ្នោតជំនួស និងការលួចបន្លំសន្លឹកឆ្នោតដែលមកទល់ពេលនេះមិនមានស្ថាប័នណាធ្វើការដោះស្រាយរកយុត្តិធម៌ឱ្យបានត្រឹមត្រូវនៅឡើយ។

តំណាងរាស្ត្រគណបក្សសមរង្ស៊ីស្នើសុំព្រះបរមរាជានុញ្ញាតផងដែរដើម្បីធ្វើសច្ចាប្រណិធានចូលកាន់តំណែងដោយឡែកដើម្បីសំដែងពីការមិនអាចទទួលយកបាននូវការលួចបន្លំ និងការរំលោភសិទ្ធិពលរដ្ឋខ្មែរដូចបានទូលថ្វាយខាងលើ និងគំរោងដឹកនាំប្រទេសជាតិឆ្ពោះទៅកាន់របបផ្តាច់ការនៃគណបក្សកាន់អំណាចតាមរយៈការគ្រប់គ្រងផ្តាច់មុខនូវស្ថាប័នជាតិទាំងឡាយ មានរដ្ឋសភាកងកម្លាំងប្រដាប់អាវុធ និងតុលាការជាដើម ហើយទូលព្រះបង្គំខ្ញុំម្ចាស់ក៏បានយល់ពីព្រះរាជហប្ញទ័យ និងស្ថានភាពដ៏លំបាកដែលព្រះករុណាជាអម្ចាស់កំពុងជួបប្រទះក្នុងព្រះរាជកិច្ចគ្រប់គ្រងរាជសម្បត្តិដោយពុំអាចផ្តល់លទ្ធភាពថ្វាយព្រះករុណាក្នុងព្រះរាជកិច្ចការពារជាតិ និងប្រជារាស្ត្ររបស់ព្រះអង្គឱ្យរស់នៅក្នុងសង្គមមួយប្រកបដោយយុត្តិធម៌ហើយប្រតិបត្តិឱ្យបានត្រឹមត្រូវនូវការគោរពសិទ្ធិមនុស្ស ការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងកិច្ចការពារបូរណភាពទឹកដី អធិបតេយ្យភាព និងឯករាជ្យភាពរបស់ជាតិខ្មែរដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលាឆ្នាំ១៩៩១ ឱ្យបានតាមព្រះរាជហប្ញទ័យនៃព្រះករុណាជាអម្ចាស់នោះ។

ទូលព្រះបង្គំ ខ្ញុំម្ចាស់ទាំងអស់គ្នាយល់ឃើញថាការដែលបានបង្គំទូលថ្វាយ និងស្នើសុំព្រះបរមរាជានុញ្ញាតខាងលើនេះ គឺធ្វើដោយគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ជាទីបំផុតនូវអង្គព្រះមហាក្សត្រ និងពុំមានលក្ខណៈណាដែលផ្ទុយពីច្បាប់ និងទំលាប់ដែលរដ្ឋសភាធ្លាប់បានអនុវត្តន៍កន្លងទៅនោះដែរ ជាមួយនឹងសេចក្តីសង្ឃឹមថា ព្រះករុណាជាអម្ចាស់ទ្រង់ព្រះមេត្តាប្រោសនឹងផ្តល់ព្រះរាជទាន និងយោគយល់បំផុតដល់ទូលព្រះបង្គំ ខ្ញុំម្ចាស់ជាប្រជានុរាស្ត្ររបស់ព្រះអង្គ។

សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវកិច្ចកតញ្ញូតាធម៌ និងស្វាមីភក្តិ ដ៏ខ្ពង់ខ្ពស់បំផុតទីទូលព្រះបង្គំ ខ្ញុំម្ចាស់។

ក្រោយពីបានទទួលនូវលិខិតរបស់អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ទាំង២៦រូបហើយ ព្រះមហាក្សត្រខ្មែរក៏បានតបមកវិញថា "*ខ្ញុំបានទទួលរួចហើយលិខិតចុះថ្ងៃទី១២ កញ្ញា ឆ្នាំ២០០៨ របស់ឯកឧត្តម និងលោកជំទាវដែលបានផ្ញើថ្វាយខ្ញុំ។ ខ្ញុំសូមជូនពរឯកឧត្តមលោកជំទាវបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនៃគណបក្សសមរង្ស៊ីបានប្រកបតែនឹងព្រះពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ*"។

ប៉ុន្តែបើសម្រាប់នាយករដ្ឋមន្ត្រីចាំផ្ទះ *ហ៊ុន សែន*វិញ បានគំរាមកំហែងៗថា ប្រសិនបើគណបក្សសមរង្ស៊ីធ្វើពហិការមិនប្រជុំសភាទេ គឺគណបក្សនេះនឹងបាត់បង់ឱកាសទទួលតួនាទីនៅក្នុងគណៈកម្មការទាំង៩របស់រដ្ឋសភាហើយ។

យ៉ាងណាក៏ដោយនៅចំពោះមុខលោកឧបការី រដ្ឋមន្ត្រីការបរទេសអាមេរិក លោក *សម រង្ស៊ី* បានមានប្រសាសន៍ថា សុំឱ្យលោក John Negroponte ជួយជម្រុញដល់រដ្ឋាភិបាល*ហ៊ុន សែន* ឱ្យទទួលស្គាល់តួនាទីនិងសិទ្ធិរបស់គណបក្សនយោបាយប្រឆាំង ក៏ដូចជាជំរុញឱ្យគណបក្សកាន់អំណាចប្រគល់តួនាទីនៅក្នុងរដ្ឋសភាមកឱ្យគណបក្សប្រឆាំងផងដែរ៕

តមកពីទំព័រ១ ន

លទ្ធផលនៃដំណើរទស្សនកិច្ចរយៈពេល៣ថ្ងៃនេះ។

ក្នុងនោះលោកឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកបានឱ្យដឹងថា ក្រសួងការបរទេសអាមេរិកមានបំណងនឹងធ្វើការពិភាក្សាជាមួយសភាដើម្បីផ្តល់ថវិកាជាលើកដំបូងចំនួន១,៨ លានដុល្លារដល់សាលាក្តីខ្មែរក្រហម។

មិនតែប៉ុណ្ណោះលោកឧបការីរូបនេះបានអះអាងថា "*យើងសង្ឃឹមថា នឹងចូលរួមយ៉ាងសកម្មជាមួយក្រុមប្រទេសផ្តល់ជំនួយដទៃទៀតដើម្បីឱ្យសាលាក្តីខ្មែរក្រហមប្រព្រឹត្តទៅបានចប់ចុងចប់ដើម និងមានការគ្រប់គ្រងត្រឹមត្រូវថែមទៀតផង*"។

ជាមួយគ្នានេះដែរ លោក John Negroponte បានសង្កត់ធ្ងន់ថា នឹងមានការដោះស្រាយឱ្យបានជ្រះស្រឡះនូវអំពើពុករលួយនិងការគ្រប់គ្រង ។សំខាន់គឺជាសេចក្តីសម្រេចដើម្បីរៀបចំគម្រោងថវិកាសម្រាប់សាលាក្តីខ្មែរក្រហមបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់សហរដ្ឋអាមេរិកក្នុងការជួយដល់ដំណើរការសាលាក្តីខ្មែរក្រហមឱ្យប្រកបដោយជោគជ័យជាស្ថាពរ ។ហើយនៅទីបញ្ចប់ប្រជាពលរដ្ឋកម្ពុជាអាចនឹងកសាងបាននូវសង្គមមួយមាននីតិរដ្ឋ។

បានសេចក្តីថាជំនួយសម្រាប់សាលាក្តីខ្មែរក្រហមគឺសហរដ្ឋអាមេរិកនឹងជួយ តែក៏មានការបង្ហាញឱ្យឃើញថា សាលាក្តីនេះគ្មានអំពើពុករលួយ ហើយការគ្រប់គ្រងត្រូវតែដោះស្រាយឱ្យជ្រះស្រឡះ។

នេះជាក្តីសង្ឃឹមថ្មីមួយទៀតរបស់សាលាក្តីខ្មែរក្រហមខណៈដែលមូលនិធិសហរដ្ឋអាមេរិកនឹងត្រូវផ្តល់មកឱ្យសាលាក្តីខ្មាតអន្តរជាតិមួយនេះជាមួយនឹងការប្រឈមយ៉ាងធ្ងន់ធ្ងរអំពីកិរិយាមិនត្រឹមត្រូវ និងអំពើពុករលួយនៅខាងភាគីកម្ពុជា។

ការចោទប្រកាន់ពីអំពើពុករលួយនេះស្ថិតក្រោមការត្រួតពិនិត្យដោយសាខាអធិការកិច្ចទូទៅរបស់សហប្រជាជាតិក្នុងក្រុងញូវយ៉ក។

ភាគីសហប្រជាជាតិរបស់សាលាក្តីនេះក៏អស់ប្រាក់ផងដែរមុនដំណាច់ឆ្នាំ២០០៨ ។ចំណែកភាគីកម្ពុជាពេលនេះត្រូវបានផ្តល់មូលនិធិត្រឹមតែខែមីនាកន្លងមកប៉ុណ្ណោះ ហើយក៏គ្មានការផ្តល់វិភាគទានបន្ថែមទៀតទេបន្ទាប់ពីមានការចោទប្រកាន់ថាមានអំពើពុករលួយត្រូវបានផ្សព្វផ្សាយជាសាធារណៈតាំងតែពីខែសីហាឆ្នាំ២០០៧មក។

គួរបញ្ជាក់ថា កន្លងមកសមាជិកសភាអាមេរិកបានជំទាស់ដាច់ខាតមិនផ្តល់មូលនិធិឱ្យតុលាការកូនកាត់នេះទេដោយរង់ចាំសេចក្តីសម្រេចពីក្រសួងការបរទេសអាមេរិកថាប្រព័ន្ធតុលាការនៅកម្ពុជាមានសមត្ថភាពពេញលេញ និងចាកផុតពីអំពើពុករលួយ និងឥទ្ធិពលនយោបាយ។ ហើយថាតុលាការនោះត្រូវតែអនុវត្តន៍ទៅតាមស្តង់ដារកាត់ទោសត្រឹមត្រូវជាអន្តរជាតិ។

ពេលនេះបើយោងតាមប្រសាសន៍លោក John Negroponte ឧបការី រដ្ឋមន្ត្រីការបរទេសអាមេរិកស្តីពីការផ្តល់ជំនួយជាលើកដំបូងដល់សាលាក្តីខ្មែរក្រហម ក្រោយពីការជួបពិភាក្សាជាមួយសភាអាមេរិកាំងហើយនោះ គឺមជ្ឈដ្ឋានជាទូទៅសង្ឃឹមថា ដំណើរការសាលាក្តីខ្មែរក្រហមនឹងឈានទៅមុខទៀតក្រោមការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់របស់អាមេរិកហើយ។

គួររំលឹកថា ជិត៣ឆ្នាំហើយដែលសាលាក្តីនេះបានលេចចេញជារូបរាង ក្រោមគំនិតផ្តួចផ្តើមរបស់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលក្រុងភ្នំពេញ ។គេបានសង្កេតឃើញថា សាលាក្តីនេះបាននាំខ្លួនអតីតមេដឹកនាំខ្មែរក្រហមចំនួន៤រូបមកឃុំខ្លួនជាបណ្តោះអាសន្ន និងបានយកអតីតមេគុកទួលស្លែង *កាំង ហ្គិចអ៊ាវ* ហៅ *ឌុច* ពីអយ្យការយោធាមកឃុំជាមួយនឹងអតីតមេដឹកនាំធំៗទាំង៤រូបទៀត ដែលរួមមាន *នួន ជា, ខៀវ សំផន, អៀង សារី* និង *អៀង*

តទៅទំព័រ៣ ន

តមកពីទំព័រ១ ក

**ក្នុងប្រទេសនេះ គឺជាកង្វល់ថា បើអំណាចរបស់គណបក្សប្រជាជន ហ៊ុន សែន នៅហួរហៀរគ្រប់គ្រងត្រួតត្រាប្រទេសនោះ គេមិនដឹងថា លទ្ធិប្រជាធិបតេយ្យនៅស្រុកខ្មែរនឹងក្លាយទៅជាអ្វីនោះទេ។**

**វាក្លាយទៅជាអ្វី ឬយ៉ាងណានោះ ក៏គេអាចយល់បានដោយមើលតម្រុយនៃភាពជិតស្និទ្ធនៃរដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន ជាមួយពួករដ្ឋាភិបាលយោធាផ្តាច់ការភូមាដែលមានលក្ខណៈនិស្ស័យប្រហាក់ប្រហែលគ្នា។ ម្យ៉ាងទៀត ហ៊ុន សែន ក៏តែងតែសម្តែងឱ្យឃើញនូវការរួមចិត្តឈឺឆ្អាលនឹងគ្នាទាំងមិនដែលហ៊ានប្រកាសអំពីការរិះគន់ដល់ការគាបសង្កត់សិទ្ធិសេរីភាពប្រជាធិបតេយ្យលើពលរដ្ឋនៃប្រទេសរៀងៗខ្លួននោះទេ។**

**លើសពីនេះទៅទៀត នរណាៗក៏គេដឹងដែរថា ហ៊ុន សែន គណបក្សប្រជាជនឡើងមកកាន់អំណាចពីដំបូងតាមរយៈមធ្យោបាយបង្ហូរឈាម ហិង្សាប្រើកាំភ្លើង និងមិនមែនប្រើគោលការណ៍លទ្ធិប្រជាធិបតេយ្យនៃការបោះឆ្នោតត្រឹមត្រូវឡើយ ហើយបន្តមកទៀតពេល ហ៊ុន សែន ឡើងកាន់អំណាចជាហូរហែ ក៏ឃើញតែគាត់នេះប្រើវិធីនៃការប្រើផ្លាកឈ្មោះបោះឆ្នោត បោកបន្លំភ្នែកប្រជារាស្ត្រ ទាំងមានការប្រើគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតឱ្យលួចប្លន់សន្លឹកឆ្នោតរបស់ប្រជារាស្ត្រ និងប្រើរូបមន្តប្លន់យកអាសនៈសភានៃគណបក្សនានាជាតំណាងរបស់ប្រជារាស្ត្រ។**

**គឺបែបនេះហើយដែល លោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ីបានមានប្រសាសន៍ថា ប្រទេសកម្ពុជានឹងអាចធ្លាក់ចូលទៅក្នុងរបបផ្តាច់ការដរាបណានៅតែស្ថិតនៅក្រោមរបៀបរបបគ្រប់គ្រងដូចពីអតីតកាលបន្តមកបច្ចុប្បន្នរបស់ ហ៊ុន សែន គណបក្សប្រជាជននោះ។ គឺថាប្រសិនបើពុំមានការយកចិត្តទុកដាក់របស់ប្រទេសម្ចាស់ជំនួយធំៗទាំងសហរដ្ឋអាមេរិក អឺរ៉ុប ទេនោះ ប្រាកដណាស់លទ្ធិប្រជាធិបតេយ្យនៅស្រុកខ្មែរក៏នឹងប្រែក្លាយទៅជាឥតន័យ ហើយប្រទេសកម្ពុជាក៏នឹងធ្លាក់ទៅក្នុងស្ថានភាពមិនខុសពីប្រទេសភូមាដែលធ្វើការជិះជាន់បង្ក្រាបសម្លាប់ប្រជារាស្ត្រឯងដើម្បីរក្សាតំណែងអំណាចរបស់ពួកមនុស្សមួយក្តាប់តូចដូចកំពុងកើតមាននៅប្រទេសភូមា ហើយដូចដែលគណបក្សប្រជាជន ហ៊ុន សែន ធ្លាប់បានបង្ហាញឱ្យប្រជារាស្ត្រខ្មែរស្គាល់ក្រយៅស្រាប់រួចមកហើយនោះ។**

**បើតាមស្តាប់សម្តី ហ៊ុន សែន អួតពីមុនការបោះឆ្នោតថា គណបក្សប្រជាជននឹងបាន៩០អាសនៈសភា ហើយឥឡូវក៏ដូចការនិយាយនោះ ក៏គេដឹងរួចជាស្រេចថា ទាំងអស់នេះជាផែនការនៃការលួចបន្លំសន្លឹកឆ្នោតរបស់គណបក្សប្រជាជន ហ៊ុន សែន តាមរយៈ គ.ជ.ប ជាឧបករណ៍របស់ខ្លួននិងអាជ្ញាធរដែនដីជាដៃជើងរបស់គណបក្ស ហ៊ុន សែន ។ហើយដោយសារអ្វីៗជាការរៀបចំទុកក្នុងគម្រោងផែនការដ៏ធំរក្សាការពារអំណាចគណបក្សប្រជាជន ហ៊ុន សែន នេះហើយទើបអ្វីជាដំណើរការលទ្ធិប្រជាធិបតេយ្យនៅស្រុកខ្មែរ ក៏ត្រូវគេខ្វល់ខ្វាយថា កំពុងរងគំនាបសង្កត់ដោយអំណាចទៅរកភាពផ្តាច់ការរបស់គណបក្សប្រជាជន ជាពិសេស ហ៊ុន សែន នោះដែរ។**

**រឿងដែលជាកង្វល់ធំជាងនេះទៅទៀតនោះ គឺប្រសិនបើកម្ពុជាអាចប្រមូលបានប្រាក់ចំណូលមួយឆ្នាំៗរាប់ពាន់លានដុល្លារពីការបូមប្រេងឆៅលក់ឱ្យបរទេសក្នុងអំឡុងឆ្នាំ២០០៩ នៅក្នុងអំណាចរដ្ឋាភិបាលអាណត្តិទី៤របស់ ហ៊ុន សែន នោះ ក្រុមអ្នកកាន់អំណាចរបស់រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែនអាចនឹងលែងស្តាប់យោបល់របស់សហគមន៍ម្ចាស់ជំនួយ។ ពេលនោះហើយដែលស្ថានភាពនៃអំណាចផ្តាច់ការនឹងរីកឥទ្ធិពលសុះសាយបំផ្លាញដំណើរការប្រជាធិបតេយ្យ ហើយប្រជារាស្ត្រខ្មែរក៏បន្តរងគ្រោះដោយសាររងគ្រោះសព្វបែបយ៉ាង ទាំងការរំលោភប្លន់យកដីធ្លី និងអំពើពុករលួយបន្តរាលដាលបំផ្លាញប្រទេសជាតិនិងពលរដ្ឋក្នុងសង្គមទាំងមូល។**

**ប្រការដ៏សំខាន់មួយទៀតនោះ គឺសហគមន៍ម្ចាស់ជំនួយអន្តរជាតិត្រូវតែឆ្លៀតពេលនេះជំរុញឱ្យមានការកែទម្រង់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ឡើងវិញ ក៏ដូចជាការប្រើប្រាស់រូបមន្តបែងចែកអាសនៈសភាឱ្យមានសមធម៌ ជាតំណាងសម្តែងពិតៗរបស់ប្រជារាស្ត្រ។ ពោលគឺរៀបចំដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមិនឱ្យនៅក្នុងកណ្តាប់ដៃនយោបាយកុម្មុយនីស្តរបស់គណបក្សប្រជាជន ហ៊ុន សែន ទៀតនោះ។ បើពុំនោះទេអ្វីៗក៏ត្រូវចប់ ហើយជីវិតលទ្ធិប្រជាធិបតេយ្យនៅស្រុកខ្មែរក៏ត្រូវរំលាយបំផ្លាញដោយអំណាចផ្តាច់ការរបស់គណបក្សប្រជាជនមិនខានឡើយ៕**